ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.៩១៣...០៤៣...០០៣...ន.ប.ក..

# ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងវិស័យធនាគារឆ្នាំ២០២២ និងទស្សនវិស័យឆ្នាំ២០២៣

រៀបចំដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃសុក្រ ១៥កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ត្រូវនឹងថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣

នាឆ្នាំ២០២២ សេដ្ឋកិច្ចពិភពលោកបានបន្តងើបឡើងដោយសារភាពធូរស្រាលនៃការរាលដាលនៃជំងឺកូវីដ-១៩ ប៉ុន្តែបញ្ហាប្រឈមមួយចំនួននៅតែបន្តមាន ដូចជា ការរអាក់រអួលនៃខ្សែច្រវាក់ផ្គត់ផ្គង់ដោយសារវិធានការបិទខ្ទប់នៅប្រទេសចិន និងការផ្ទុះឡើងសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ដែលធ្វើឱ្យទំនិញឡើងថ្លៃ ជាពិសេសប្រេងឥន្ធនៈនិងវត្ថុធាតុដើម។ កត្តាទាំងនេះបានធ្វើឱ្យអត្រាអតិផរណាសកលបានហក់ឡើងខ្ពស់ដល់ ៨,៨% (ធៀបនឹង ៣,៥% ឆ្នាំ២០២១) ទាំងក្នុងប្រទេសអភិវឌ្ឍន៍និងកំពុងលូតលាស់ (មានកម្រិត ៧,២% និង ៩,៩% រៀងគ្នា)។ ដើម្បីទប់ស្កាត់ការកើនឡើងនេះ ធនាគារកណ្តាលភាគច្រើនបានដំឡើងអត្រាការប្រាក់គោលក្នុងគោលបំណងកាត់បន្ថយតម្រូវការសម្រាប់ការវិនិយោគនិងការប្រើប្រាស់។ ជាក់ស្តែង ធនាគារកណ្តាលអាមេរិកបានដំឡើងអត្រាការប្រាក់គោលលឿនជាងការរំពឹងទុក ដែលបានទាក់ទាញមូលធនឱ្យហូរចូលទៅក្នុងសហរដ្ឋអាមេរិក និងបណ្តាលឱ្យប្រាក់ដុល្លារអាមេរិកឡើងថ្លៃគួរឱ្យកត់សម្គាល់។ ការហូរចេញនេះ បានដាក់សម្ពាធទៅលើតម្លៃរូបិយប័ណ្ណ ទុនបម្រុងអន្តរជាតិធនាគារកណ្តាល និងលទ្ធភាពសងបំណុល ជាពិសេសសម្រាប់ប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍។ បញ្ហាទាំងនេះបាននាំឱ្យកំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានប៉ាន់ស្មានថាថយចុះត្រឹម ៣,២% ធៀបនឹងការរំពឹងទុក ៤,៤% កាលពីដើមឆ្នាំ២០២២។

នៅកម្ពុជា ប្រសិទ្ធភាពនៃការគ្រប់គ្រងវិបត្តិជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាល បានធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកវិលទៅរកប្រក្រតីភាពនាឆ្នាំ២០២២នេះ។ ការដាក់ចេញវិធានការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាបន្តបន្ទាប់ ជាពិសេស ក្របខ័ណ្ឌយុទ្ធសាស្ត្រនិងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣ និងការបន្ធូរបន្ថយបទប្បញ្ញត្តិក្នុងវិស័យធនាគារ បានជួយគាំទ្រនិងពន្លឿនការងើបឡើងនៃសេដ្ឋកិច្ចកម្ពុជា។ ស្ថានភាពអំណោយផលក្នុងស្រុកនិងកំណើនតម្រូវការខាងក្រៅ បានជួយគាំទ្រឱ្យសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២២ បន្តងើបឡើងក្នុងអត្រា ៥,១%។ ការកើនឡើងនេះអាស្រ័យលើកំណើនក្នុងវិស័យកម្មន្តសាលដែលត្រូវបានប៉ាន់ស្មានថាសម្រេចបានក្នុងអត្រា ៩,៤% សណ្ឋាគារនិងភោជនីយដ្ឋានកើន ១៥,២% ការដឹកជញ្ជូនអាចកើន ៦,១% និងអាជីវកម្មលក់ដុំនិងរាយ ៤,៥%។ ទន្ទឹមនេះ ការនាំចេញបានកើនឡើងល្អប្រសើរក្នុងអត្រា ១៩,៨% លឿនជាងកំណើនការនាំចូល ៨% ហើយចំណូលពីវិស័យ



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ទេសចរណ៍បានកើន ៦,៦ដង ស្របពេលដែលប្រាក់បង្វែររបស់ពលករពីក្រៅប្រទេសបានកើនឡើង ៥%។ម្យ៉ាងទៀត លំហូរវិនិយោគផ្ទាល់បរទេសទទួលបានកំណើនវិជ្ជមានមកវិញជាមួយនឹងអត្រា ៥% ដែលជាចម្បងទៅកាន់វិស័យកាត់ដេរ និងការកែច្នៃម្ហូបអាហារ បើទោះជាលំហូរទៅកាន់វិស័យមួយចំនួនទៀតបានថយចុះក៏ដោយ។

ការកើនឡើងនៃវិនិយោគផ្ទាល់បរទេស និងការនាំចេញបានជួយបន្ថយសម្ពាធលើការថយចុះទុនបម្រុងអន្តរជាតិរបស់កម្ពុជា។ ទោះមានការថយចុះបន្តិចក៏ដោយ ទុនបម្រុងអន្តរជាតិមានកម្រិត ៧ខែ នៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់ ខ្ពស់ជាងកម្រិតដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន (៣ខែ)។ កម្រិតគ្រប់គ្រាន់នៃទុនបម្រុងអន្តរជាតិបានគាំទ្រដល់ការអនុវត្តនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់ ដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់និងផ្គត់ផ្គង់សាច់ប្រាក់ក្នុងកម្រិតសមស្រប សំដៅរក្សាស្ថិរភាពថ្លៃនិងឆ្លើយតបនឹងតម្រូវការសេដ្ឋកិច្ច។ អត្រាប្តូរប្រាក់រៀល ធៀបនឹងដុល្លារអាមេរិកត្រូវបានរក្សាឱ្យមានស្ថិរភាពក្នុងរង្វង់ ៤.១០២ ដែលថយថ្លៃត្រឹម ០,១% ប៉ុណ្ណោះធៀបនឹងឆ្នាំមុន។ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ២០២២ បានកើនឡើងដល់ ៥,៣% ខ្ពស់ជាងឆ្នាំ២០២១ (២,៩%) ដោយសារការកើនឡើងនៃថ្លៃប្រេងឥន្ធនៈនិងម្ហូបអាហារ។ គួររំលេចថា អត្រាអតិផរណាបានកើនឡើងខ្ពស់ដល់ ៧,៨% នៅចុងឆមាសទី១ ប៉ុន្តែបានថយចុះជាបន្តបន្ទាប់នៅឆមាសទី២ ស្របពេលដែលថ្លៃប្រេងឥន្ធនៈនិងម្ហូបអាហារបានថយចុះមកវិញ។

ប្រព័ន្ធធនាគារបានដើរតួនាទីយ៉ាងសកម្ម ដើម្បីបន្តគាំទ្រការងើបឡើងវិញនៃសេដ្ឋកិច្ច តាមរយៈការបន្តផ្តល់សេវាហិរញ្ញវត្ថុសមស្រប ដើម្បីឆ្លើយតបនឹងតម្រូវការសេដ្ឋកិច្ច។ ឥណទានទៅកាន់វិស័យឯកជនបានកើនឡើង ២១% ដែលត្រូវបានបែងចែកទៅគាំទ្រដល់ការងើបឡើងក្នុងវិស័យសំខាន់ៗនៃសេដ្ឋកិច្ចជាតិ ខណៈដែលកំណើនប្រាក់បញ្ញើអតិថិជនបានកើនឡើង ១១,៣%។ បទប្បញ្ញត្តិប្រុងប្រយ័ត្នដែលត្រូវបានបន្ធូរបន្ថយនៅក្នុងពេលមានវិបត្តិដើម្បីសម្រាលបន្ទុកអ្នកខ្ចីប្រាក់និងរក្សានិរន្តរភាពឥណទានទៅកាន់សេដ្ឋកិច្ច ត្រូវបានពង្រឹងជាលំដាប់មកវិញ ស្របតាមការងើបឡើងនៃសេដ្ឋកិច្ច ដែលជាផ្នែកមួយនៃគោលនយោបាយចាកចេញពីវិបត្តិ ដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុនិងបង្កើនទ្រនាប់គោលនយោបាយសម្រាប់អនុវត្តក្នុងស្ថានភាពចំបាច់។ ការរៀបចំឥណទានឡើងវិញ ត្រូវបានបញ្ឈប់នៅចុងឆមាសទី១ ហើយចំនួនទឹកប្រាក់នៃការរៀបចំឥណទានឡើងវិញបានថយចុះយ៉ាងឆាប់រហ័សពី ១០,៥% មក ៦% នៃសំពៀតឥណទានសរុប។ ជាមួយគ្នានេះ ប្រព័ន្ធទូទាត់ត្រូវបានបន្តធ្វើទំនើបកម្ម ដើម្បីបង្កើនប្រសិទ្ធភាពការទូទាត់និងផ្ទេរប្រាក់ទាំងក្នុងស្រុកនិងអន្តរជាតិ ដោយបច្ចុប្បន្នគណនីអ៊ីវ៉ាឡេតបានកើនឡើងដល់ចំនួន ១៧,៩ លានគណនី។ ការតភ្ជាប់ក្នុងតំបន់ត្រូវបានពង្រីកជាលំដាប់ជាមួយប្រទេសក្នុងតំបន់ ដែលសម្រួលដល់អន្តរប្រតិបត្តិការរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជំរុញពាណិជ្ជកម្ម ការវិនិយោគ និងទេសចរណ៍។

នាឆ្នាំ២០២៣ ការបើកសេដ្ឋកិច្ចឡើងវិញនៃប្រទេសនានាបន្តគាំទ្រការងើបឡើងនៃពាណិជ្ជកម្ម ទេសចរណ៍ និងការវិនិយោគ ប៉ុន្តែសេដ្ឋកិច្ចពិភពលោកនៅបន្តប្រឈមនឹងភាពមិនច្បាស់លាស់ច្រើន។

មូលនិធិរូបិយវត្ថុអន្តរជាតិបានរំពឹងថាសេដ្ឋកិច្ចពិភពលោកនឹងអាចមានកំណើនត្រឹម ២,៧% ទាបជាងឆ្នាំ២០២២ (៣,២%)។ ការអូសបន្លាយនៃវិបត្តិសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន គឺជាហានិភ័យចម្បងមួយដែលអាចបន្តប៉ះពាល់ដល់ខ្សែច្រវាក់ផ្គត់ផ្គង់និងដាក់សម្ពាធលើអតិផរណា។ ក្នុងស្ថានភាពដែលអត្រាអតិផរណានៅមានកម្រិតខ្ពស់នៅឡើយ ធនាគារកណ្តាលសហរដ្ឋអាមេរិកគ្រោងបន្តដំឡើងអត្រាការប្រាក់គោលបន្ថែមទៀត ដែលអាចបន្តរឹតបន្តឹងទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ព្រមទាំងបណ្តាលឱ្យប្រាក់ដុល្លារអាមេរិកបន្តឡើងថ្លៃ។ ជាមួយគ្នានេះ ពិភពលោកក៏ត្រូវបន្តដោះស្រាយបញ្ហាដែលនៅដក់សល់ពីវិបត្តិជំងឺកូវីដ-១៩ ដូចជា ការកើនឡើងបំណុលសាធារណៈនិងឯកជន ភាពមិនច្បាស់លាស់លើការអនុវត្តវិធានការតឹងរ៉ឹងដើម្បីគ្រប់គ្រងការរាលដាលមេរោគបំប្លែងកូវីដ-១៩ និងការប្រែប្រួលអាកាសធាតុ ជាដើម ដែលជាបញ្ហាប្រឈមដ៏សក្តានុពល ចំពោះការងើបឡើងនៃសេដ្ឋកិច្ចផងដែរ។

ចំពោះសេដ្ឋកិច្ចកម្ពុជា កំណើនត្រូវបានរំពឹងដោយសុទិដ្ឋិនិយមថានឹងបន្តសម្រេចបានក្នុងរង្វង់ ៦% នៅឆ្នាំ២០២៣ បើទោះជាមានបញ្ហាប្រឈមខាងក្រៅខ្ពស់ក៏ដោយ។ កំណើននេះសម្រេចបានដោយសារការរំពឹងទុកពីកំណើនក្នុងវិស័យកាត់ដេរ ៦,៩% ហើយផលិតផលកម្មន្តសាលមិនមែនកាត់ដេរកើន ១៤,៣%។ វិស័យទេសចរណ៍ត្រូវបានរំពឹងថានឹងមានកំណើន ១៨,៥% ដោយសារកំណើនភ្ញៀវទេសចរក្នុងស្រុកនិងការងើបឡើងលឿននៃភ្ញៀវទេសចរអន្តរជាតិ ជាមួយនឹងការបង្កើនការតភ្ជាប់ជើងហោះហើរមកកម្ពុជាជាលំដាប់និងការកើនឡើងទេសចរចិន ក្រោយការបន្ធូរបន្ថយការរឹតបន្តឹងលើការធ្វើដំណើរ ដើម្បីការពារការរាលដាលជំងឺកូវីដ-១៩ របស់រដ្ឋាភិបាលចិន។ វិស័យកសិកម្មត្រូវបានព្យាករថានឹងមានកំណើនល្អជាងឆ្នាំ២០២២ ក្នុងអត្រា ១,១% ដែលរួមចំណែកគាំទ្រដោយការចូលជាធរមាននៃកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី ព្រមទាំងការដកបាំងពន្ធនាំចូលអង្ករបស់កម្ពុជាទៅកាន់ទីផ្សារអឺរ៉ុប។ យ៉ាងណាមិញ វិស័យសំណង់និងអចលនទ្រព្យត្រូវបានរំពឹងថានឹងបន្តងើបឡើងជាសន្សឹមៗ ក្នុងអត្រា ១,៧% និង ១,២% រៀងគ្នា ដែលគាំទ្រដោយកំណើនតម្រូវការក្នុងស្រុកផ្តោតលើទីផ្សារអចលនទ្រព្យលំនៅឋានដែលមានតម្លៃសមរម្យ ខណៈដែលសំណង់ប្រភេទប្រណីតដែលបម្រើដល់តម្រូវការអនិវាសជនត្រូវការពេលវេលា ដើម្បីអាចវិលត្រឡប់ទៅរកស្ថានភាពមុនពេលមានវិបត្តិ។

អតិផរណានៅឆ្នាំ២០២៣ អាចប្រឈមនឹងភាពមិនប្រាកដប្រជា ដោយសារការអូសបន្លាយសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចពិភពលោក។ ក្នុងស្ថានភាពដែលសេដ្ឋកិច្ចពិភពលោកអាចមានកំណើនទាបជាមួយនឹងការថយល្បឿនកំណើនថ្លៃម្ហូបអាហារ អតិផរណាត្រូវបានព្យាករថាថយចុះមកត្រឹម ២,៥%។ គួរបញ្ជាក់ថា ក្នុងក្របខ័ណ្ឌដុល្លាររូបនីយកម្មខ្ពស់ ការរក្សាស្ថិរភាពប្រាក់រៀលជាកត្តាសំខាន់ ដើម្បីសម្រេចគោលដៅរក្សាស្ថិរភាពអតិផរណា។ ជាពិសេស ស្ថិរភាពប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបានជួយការពារអំណាចទិញ ចំណូលរបស់ប្រជាជនដែលមានចំណូលជាប្រាក់រៀល និងរួមចំណែកបន្ទាបតម្លៃទំនិញនាំចូល។ ក៏ប៉ុន្តែ ការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិកក៏ធ្វើឱ្យថ្លៃទំនិញនាំចេញពីកម្ពុជាមានកម្រិតខ្ពស់ជាងមុន បើគិតជារូបិយប័ណ្ណនៅក្នុងប្រទេសជាទីផ្សារនាំទំនិញចូលពីកម្ពុជា ដែលនេះអាចជាការប្រឈមមួយទៀតសម្រាប់កម្ពុជា។

ម្យ៉ាងទៀត ការរឹតត្បិតស្ថានភាពទីផ្សារហិរញ្ញវត្ថុអន្តរជាតិនឹងបន្ថយលទ្ធភាពទទួលបានការខ្ចីពីក្រៅប្រទេសរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជា វិស័យឯកជន។ បញ្ហានេះ ក៏នឹងអាចនាំឱ្យអត្រាការប្រាក់នៅកម្ពុជាកើនឡើងផងដែរ ប្រសិនបើការរឹតត្បិតមានរយៈពេលយូរនាពេលខាងមុខ ស្របពេលដែលភាពរឹតត្បិតនិងភាពមិនប្រាកដប្រជានៃទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ក៏អាចនាំឱ្យទុនបម្រុងអន្តរជាតិបន្តប្រឈមនឹងសម្ពាធជាច្រើន។ ទោះយ៉ាងណា ការងើបឡើងនៃសេដ្ឋកិច្ចក្នុងស្រុកត្រូវបានរំពឹងថាអាចគាំទ្រទុនបម្រុងអន្តរជាតិឱ្យកើនឡើង និងស្ថិតក្នុងកម្រិតគ្រប់គ្រាន់ប្រមាណ ៧ខែ នៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់ ដោយសារកំណើនលំហូរចូលនៃវិនិយោគផ្ទាល់បរទេស ការនាំចេញ ទេសចរណ៍ និងការបង្វែរចូលនានា។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh
**បណ្ដាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.org.kh , www.facebook.com/nationalbankofcambodiaofficial ,
www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia ,
www.linkedin.com/company/national-bank-of-cambodia ,
www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA